

# ការសើបអង្កេតក្នុងរឿងទាក់ទិនជាមួយកុមារតូចនៃសហគមន៍ដែល មានវប្បធម៌ និងភាសាចម្រុះ (CALD)

រដ្ឋសភារដ្ឋវិចថូរៀ កំពុងធ្វើការសើបអង្កេតក្នុងរឿងទាក់ទិនជាមួយ កុមារតូចនៃក្រុមគ្រួសារដែលមានវប្បធម៌ និងភាសាចម្រុះ។

ការទាក់ទិនជាមួយកុមារតូច គឺចាប់ពីអាយុ ០ ទៅ ៨ ឆ្នាំ ហើយអាចពាក់ព័ន្ធនឹងកម្មវិធី និងសេវាកម្មទាក់ទិននឹងសុខភាព ការរៀនសូត្រ ការថែទាំកុមារ ក្រុមលេងសម្រាប់កុមារ មជ្ឈមណ្ឌលគ្រួសារ កីឡា និងការកម្សាន្ត និងបណ្ណាល័យក្នុងតំបន់។ យើងខ្ញុំចង់ដឹងឮពីបទពិសោធន៍ និងគំនិតរបស់អ្នកអំពី៖

- តើអ្នកប្រើប្រាស់សេវាកម្មអ្វីខ្លះ ? ( ឧទាហរណ៍មួយចំនួនមាន គិលានុបដ្ឋាកសុខភាពមាតា មត្តេយ្យសាលា ក្រុមលេងសម្រាប់កុមារ )
- តើសេវាកម្មទាំងនេះផ្ដល់គុណប្រយោជន៍ដល់កូន និងគ្រួសាររបស់អ្នកដូចម្ដេចដែរ ?
- តើគេអាចកែលម្អសេវាកម្មទាំងនេះដោយបែបណា ?
- តើអ្នកបានទទួលព័ត៌មានគ្រប់គ្រាន់អំពីសេវាកម្មទាំងនេះឬទេ ?
- តើមានអ្វីខ្លះដែលបញ្ឈប់អ្នកពីការចូលរួមក្នុងសេវាកម្មទាំងនេះ ?
- តើមានជំនួយអ្វីផ្សេងទៀតដែលអ្នកត្រូវការ ខណៈពេលដែលកូនៗរបស់អ្នកនៅវ័យក្មេង ?
- តើកូន និងគ្រួសាររបស់អ្នកមានអារម្មណ៍ទាក់ទងជាមួយសហគមន៍ក្នុងតំបន់ដូចម្ដេចដែរ ?

ការដាក់ស្នើអាចគ្របដណ្ដប់សំណួរទាំងនេះណាមួយ ឬទាំងអស់។

សម្រាប់ព័ត៌មានបន្ថែមស្ដីពីការដាក់ស្នើ សូមចូលទៅកាន់វ៉ិបសៃថ៍៖ **parliament.vic.gov.au/caldchildinquiry**

ការដាក់ស្នើអាចធ្វើឡើងរហូតដល់ថ្ងៃទី **11** ខែតុលា ឆ្នាំ **2019**។

ប្រសិនបើអ្នកត្រូវការជំនួយក្នុងការសរសេរជាភាសាអង់គ្លេស ឬមានសំណួរណាមួយ សូមទាក់ទងមកយើងខ្ញុំតាមរយៈអ៊ីម៉េល **caldchildinquiry@parliament.vic.gov.au** ឬទូរស័ព្ទ **(03) 8682 2846**.

គ្រប់ការដាក់ស្នើទាំងអស់ត្រូវបានចាត់ទុកជាឯកសារសាធារណៈ លុះត្រាតែបានស្នើសុំទុកជាការសម្ងាត់ ហើយបានទទួលការផ្ដល់ជូន។